**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៤៣ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី៦ កក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១.-**

ត្រូវបានបង្កើត“**គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា**” ហៅកាត់“**គ.ជ.ផ.ក.**” ជាសេនាធិការរបស់រាជរដ្ឋាភិបាល នៅក្រោមគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលទទួលបន្ទុកដឹកនាំ អភិវឌ្ឍ និងជំរុញផលិតភាពជាតិសរុប ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

## ជំពូកទី២

## សមាសភាព

**មាត្រា២.-**

**គ.ជ.ផ.ក.** មានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| ១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | ប្រធាន |
| ២-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម | | អនុប្រធាន |
| ៣-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | | អនុប្រធាន |
| ៤-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | អនុប្រធាន |
| ៥-រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | អនុប្រធាន |
| ៦-រដ្ឋមន្ត្រីក្រសួងផែនការ | | សមាជិក |
| ៧-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | សមាជិក |
| ៨-រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | | សមាជិក |
| ៩-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | សមាជិក |
| ១០-រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | សមាជិក |
| ១១-រដ្ឋមន្ត្រីក្រសួងសុខាភិបាល | | សមាជិក |
| ១២-រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | | សមាជិក |
| ១៣-រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | | សមាជិក |
| ១៤-រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល | | សមាជិក |
| ១៥-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | | សមាជិក |
| ១៦-រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | | សមាជិក |
| ១៧-អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា | | សមាជិក |
| ១៨-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១(មួយ)រូប | សមាជិក |
| ១៩-រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១(មួយ)រូប | សមាជិក |
| ២០-តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | ១(មួយ)រូប | សមាជិក |
| ២១-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | សមាជិក |
| ២២-តំណាងប្រតិបត្តិករសេដ្ឋកិច្ច | ៣(បី)រូប | សមាជិក |
| ២៣-តំណាងមជ្ឈដ្ឋានសិក្សាស្រាវជ្រាវ | ៣(បី)រូប | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.ជ.ផ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទី និងភារកិច្ច

**មាត្រា៣.-**

**គ.ជ.ផ.ក.** មានតួនាទី និងភារកិច្ច ដូចតទៅ÷

- ដឹកនាំនិងរៀបចំគោលនយោបាយ សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ ដើម្បីជំរុញផលិតភាពជាតិសរុប និងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ
- សហការជាមួយក្រសួងស្ថាប័ន និងដៃគូពាក់ព័ន្ធ ក្នុងគោលដៅរៀបចំ សម្រិតសម្រាំង និងធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ សំដៅបង្កើនផលិតភាពជាតិសរុប និងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ
- បង្កើតនិងអនុវត្តកម្មវិធីវិទ្យាសាស្ត្រទិន្នន័យ ការសិក្សាស្រាវជ្រាវទីផ្សារ ការវិភាគទិន្នន័យ និងវិទ្យាសាស្ត្រគោលនយោបាយ ដើម្បីធានាបានភាពច្បាស់លាស់ ភាពប្រាកដនិយម ភាពឆ្លើយតប និងប្រសិទ្ធភាពនៃគោលនយោបាយពាក់ព័ន្ធផលិតភាពសេដ្ឋកិច្ច
- បំពេញភារកិច្ចផ្សេងទៀតតាមការសម្រេចរបស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៤
## បែបបទដំណើរការការងារ

**មាត្រា៤.-**

អនុប្រធាន និងសមាជិករបស់ **គ.ជ.ផ.ក.** ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬត្រូវចាត់តាំងតំណាងដែលមានសិទ្ធិសម្រេច ដើម្បីចូលរួមប្រជុំជំនួសក្នុងករណីអវត្តមាន។

**គ.ជ.ផ.ក.** ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ការបំពេញការងារ។

**មាត្រា៥.-**

**គ.ជ.ផ.ក.** មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ ឬតំណាងនៃក្រសួងស្ថាប័នពាក់ព័ន្ធ ឬឥស្សរជនដែលមានបទពិសោធន៍ សមត្ថភាព និងជំនាញវិជ្ជាជីវៈ ចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ **គ.ជ.ផ.ក.** តាមការចាំបាច់។

**គ.ជ.ផ.ក.** មានសិទ្ធិអញ្ជើញតំណាងក្រសួងស្ថាប័នសាធារណៈ តំណាងវិស័យឯកជន តំណាងដៃគូអភិវឌ្ឍន៍ តំណាងអង្គការវិជ្ជាជីវៈ តំណាងសង្គមស៊ីវិល ទីប្រឹក្សា ឬអ្នកជំនាញការជាតិនិងអន្តរជាតិ ដើម្បីប្រឹក្សា និងពិភាក្សាយោបល់ តាមការចាំបាច់។

**មាត្រា៦.-**

**គ.ជ.ផ.ក.** ត្រូវទទួលបានការគាំទ្រ និងកិច្ចសហប្រតិបត្តិការពេញលេញពីក្រសួងស្ថាប័ននៅគ្រប់ជាន់ថ្នាក់។ គ្រប់ក្រសួងស្ថាប័ន និងអ្នកពាក់ព័ន្ធមានកាតព្វកិច្ចផ្តល់ឯកសារ ព័ត៌មាន ទិន្នន័យ និងកិច្ចសហប្រតិបត្តិការចាំបាច់នានា ជូនដល់ **គ.ជ.ផ.ក.**។

## ជំពូកទី៥
## រចនាសម្ព័ន្ធគាំទ្រ

**មាត្រា៧.-**

**គ.ជ.ផ.ក.** មានអគ្គលេខាធិការដ្ឋានមួយ ជាសេនាធិការសម្រាប់គាំទ្រការបំពេញតួនាទី ភារកិច្ច និងកិច្ចដំណើរការការងាររបស់ខ្លួន។

អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** ត្រូវដឹកនាំដោយអគ្គលេខាធិការ ១(មួយ)រូប និងមានអគ្គលេខាធិការរង ២(ពីរ)រូប។

អគ្គលេខាធិការ **គ.ជ.ផ.ក.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ និងអគ្គលេខាធិការរង **គ.ជ.ផ.ក.** ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាន **គ.ជ.ផ.ក.**។

អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** អាចមានទីប្រឹក្សា អ្នកជំនាញ ឬបុគ្គលិកជាប់កិច្ចសន្យា ដើម្បីជួយបំពេញការងាររបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** មានទីតាំងនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** មានប្រភពធនធានថវិកាផ្គត់ផ្គង់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការជាតិនិងអន្តរជាតិ និងពីប្រភពស្របច្បាប់ផ្សេងៗទៀត តាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

អនុក្រឹត្យនេះ ត្រូវជំនួសអនុក្រឹត្យដូចខាងក្រោម÷

- អនុក្រឹត្យលេខ ២៦៧ អនក្រ.បក ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការផលិតភាពកម្ពុជា

- អនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យឯកជន។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១៤ រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ